**ទំនាក់ទំនង ៖** Jonathan Kaufman (ប្រចាំទីក្រុងវ៉ាស៊ីតុន): +1 202-466-5188 x113, jonathan@earthrights.org
Maureen Harris (ប្រចាំប្រទេសថៃ): +66 846 122 256, maureen@earthrights.org
មេធាវី នី សោភ័ណ្ឌនារី (ប្រចាំប្រទេសកម្ពុជា), +855 66 777 027, sorphonneary@clec.org.kh
លោក អៀង វុទ្ធី (ប្រចាំប្រទេសកម្ពុជា), +855 12 791 700, vuthy@equitablecambodia.org

# សមាគម BONSUCRO បានព្យួរសមាជិកភាពរបស់ក្រុមហ៊ុន TATE & LYLE ដោយសារបញ្ហារំលោភយកដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

*ក្រុមហ៊ុនស្ករសនៃចក្រភពអង់គ្លេសត្រូវបានចោទប្រកាន់ពីការទទួលប្រយោជន៍ពីការរំលោភយកដី។ ប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងទៅចក្រភពអង់គ្លេស បន្ទាប់ពីក្រុមហ៊ុនមេ American Sugar Refining ដើរចេញពីដំណើរការសន្ទានកម្ម។*

*ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣*

កាលពីម្សិលមិញ ក្រុមប្រឹក្សាភិបាលនៃសមាគមស្ករស Bonsucro បានធ្វើការប្រកាសសេចក្តីសម្រេចរបស់ខ្លួនក្នុងការព្យួរសមាជិកភាពរបស់ក្រុមហ៊ុន Tate & Lyle Sugars (TLS) ដោយសារមានបណ្តឹងប្រឆាំងនឹងក្រុមហ៊ុនស្ករសដ៏ធំរបស់ចក្រភពអង់គ្លេស ពីការទទួលប្រយោជន៍ពីការរំលោភយកដីប្រជាពលរដ្ឋដោយខុសច្បាប់ តាមរយៈការទិញស្ករសនៅខេត្តកោះកុង ព្រះរាជាណាចក្រកម្ពុជា។ ដោយសារពាក្យបណ្តឹងទៅរដ្ឋាភិបាលអាមេរិក និង សហគមន៍អឺរ៉ុប រួមទាំង បណ្តឹងទៅតុលាការចក្រភពអង់គ្លេស បានបង្កើនការដាក់សំពាធដល់ក្រុមហ៊ុន TLS ក្នុងការផ្តល់យុត្តិធម៌ដល់សហគមន៍ដែលរងផលប៉ះពាល់។

ដីចំការអំពៅនៅខេត្តកោះកុង គឺបានមកពីការបណ្តេញចេញដោយបង្ខំ និង ករណីខ្លះ ជាការរឹបអូស ដោយហិង្សាពីប្រជាពរដ្ឋជាង ៤៥០គ្រួសារ នៅឆ្នាំ២០០៦ ហើយដីទាំងនេះត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុន Khon Kaen Sugar Ltd., ដែលជាក្រុមហ៊ុនថៃ ទទួលបានសិទ្ធិលក់ផ្តាច់មុខតាមរយៈកិច្ចសន្យាជាមួយក្រុមហ៊ុន TLS ។ ការរំលោភយកដីនេះ ត្រូវបានចងក្រងជាឯកសារជាច្រើន ដោយអ្នកស្រាវជ្រាវឯករាជ្យ រួមទាំងការិយាល័យឧត្តមស្នងការនៃអង្គសហប្រជាជាតិប្រចាំកម្ពុជា។ លោកស្រី **នី សោភ័ណ្ឌនារី** ជាមេធាវីប្រចាំមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងជាមេធាវីតំណាងដោយអាណត្តិរបស់ប្រជាពលរដ្ឋនៅតុលាការក្នុងស្រុក និងជាអ្នកគាំទ្រដាក់បណ្តឹងទៅតុលាការចក្រភពអង់គ្លេស បានមានប្រសាសន៍ថា "ដីនេះ គឺមានន័យណាស់សម្រាប់ប្រជាពលរដ្ឋទាំងនេះ ពួកគេកំពុងតែជួបប្រទះនឹងបញ្ហាជីវិត ដូចជា គ្មានប្រភពអាហារ ចំណូល និង សុន្តិសុខ។ ពួកគាត់នឹងបន្តប្តឹងទាមទារសិទ្ធិរបស់ពួកគាត់នៅគ្រប់យន្តការដែលពាក់ព័ន្ធ"។

សមាគម Bonsucro បានធ្វើការជាមួយសមាជិកខ្លួន ក្នុងការបង្កើននិរន្តភាព និង ផលប៉ះពាល់ផ្នែកបរិស្ថានចំពោះផលិតផលស្ករអំពៅ។ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និង អង្គការសមធម៌កម្ពុជា បានដាក់ពាក្យបណ្តឹងទៅសមាគម Bonsucro កាលពីពីរឆ្នាំមុន។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលបានធ្វើឡើង បន្ទាប់ពីក្រុមហ៊ុន TLS បានធ្វើការបដិសេធក្នុងការសហការនៅក្នុងដំណើរការដោះស្រាយទំនាស់ ដូចជា ការបដិសេធមិនផ្តល់ព័ត៍មាន និង អើពើចំពោះសំណើសុំឲ្យត្រួតពិនិត្យបញ្ជាសំណងដែលបានផ្តល់ឲ្យប្រជាពលរដ្ឋមួយចំនួន។ លោក **អៀង វុទ្ធី** នាយកប្រតិបត្តិនៃអង្គការសមធម៌កម្ពុជា បានលើកឡើងថា "យើងសង្ឃឹមថា ក្រុមហ៊ុន Tate & Lyle នឹងចូលរួមសហការក្នុងការកែតម្រូវភាពអយុត្តិធម៌ ប៉ុន្តែយើងក៏អបអរសាទរចំពោះក្រុមប្រឹក្សាភិបាលរបស់សមាគម Bonsucro ដែលបានចាត់ដំណើរការដោយភាពស្មោះត្រង់ និងគោរពទៅតាមក្រមសីលធម៌របស់ខ្លួន"។

ក្រុមហ៊ុនចម្រាញ់ស្ករសរបស់អាមេរិក (American Sugar Refining) ដែលជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុន Tate & Lyle ក៏បានសម្រេចចិត្តដកខ្លួនមិនសហការនៅក្នុងដំណើរការដោះស្រាយទំនាស់ ដែលប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងកាលពីឆ្នាំមុន ទៅរដ្ឋាភិបាលសហរដ្ឋអាមេរិក OECD Guideline ដែលជាយន្តការសម្រាប់សហគ្រាសអន្តរជាតិនៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច។ ទោះបីជា យន្តការ

នេះបានរកឃើញថា ពាក្យបណ្តឹងរបស់អ្នកភូមិ គឺត្រឹមត្រូវ និង ផ្តល់ឲ្យមានសន្ទានកម្មក៏ដោយ ក៏ក្រុមហ៊ុនចម្រាញ់ស្ករសរបស់អាមេរិក (American Sugar Refining) បានដកខ្លួនចេញពីកិច្ចដំណើរការនេះ ក្រោយពេលប្រជាពលរដ្ឋបដិសេធមិនព្រមបោះបង់ពាក្យបណ្តឹងប្រឆាំងនឹងក្រុមហ៊ុន TLS។ សេចក្តីសម្រេចចុងក្រោយរបស់យន្តការដំណោះស្រាយជំនាស់នេះ បានចេញនៅក្នុង ខែមិថុនា ស្នើឲ្យក្រុមហ៊ុនចម្រាញ់ស្ករសរបស់អាមេរិក (American Sugar Refining) "រៀបចំត្រួតពិនិត្យគោលនយោបាយគោរពសិទ្ធិមនុស្សចំពោះវិស័យពាណិជ្ជកម្ម"។

ទោះបីជាយ៉ាងណា ការបដិសេធមិនព្រមចូលរួមដោះស្រាយនេះ មិនបានធ្វើឲ្យក្រុមហ៊ុន TLS មានការព្រួយបារម្ភពីបញ្ហាច្បាប់ទាំងនោះឡើយ។ ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋប្រឆាំងនឹងក្រុមហ៊ុន TLS នៅតុលាការចក្រភពអង់គ្លេស បាននឹងកំពុងដំណើរការបន្ត បន្ទាប់ពីការសម្រុះសម្រួលកាលពីថ្ងៃទី៥ ខែកក្កដា បានបរាជ័យ។ បណ្តឹងនេះទាមទារសំណងលើផលិតផលស្ករសដែលផលិតបានពីដីសហគមន៍។

លោក Janathan Kaufman ដែលជាមេធាវីរបស់អង្គការ Earth Rights International បានថ្លែងថា "ជារៀងរាល់លើកដែលសហគមន៍បានព្យាយាមទំនាក់ទំនងជាមួយក្រុមហ៊ុន Tate and Lye និង ASR ប៉ុន្តែកិច្ចប្រឹងប្រែងរបស់ពួកគេត្រូវបានទាត់ចោល។ ក្រុមហ៊ុនគួរទទួលបានសមាជិកភាពពីសមាគម Bunsocro វិញ ប្រសិនបើក្រុមហ៊ុនព្រមប្រគល់ដី ឬសំណងដោយយុត្តិធម៌ ដល់ប្រជាពលរដ្ឋ។ បើមិនដូច្នេះទេ ការសម្រេចនឹងជាសមត្ថកិច្ចរបស់តុលាការរបស់ចក្រភពអង់គ្លេស ថាតើក្រុមហ៊ុនរបស់លោកខាងលិចអាចទទួលផលប្រយោជន៍ពីការឆក់យកដីនៅប្រទេសកម្ពុជាដែរឬទេ"។

ប្រជាពលរដ្ឋ និង អ្នកជួយគាំទ្រពួកគេ បានស្វែងរកកិច្ចចរចារជាមួយក្រុមហ៊ុនជាច្រើនលើកច្រើនសារ និង បានដាក់ពាក្យបណ្តឹងទៅតុលាការក្នុងស្រុក តុលាការចក្រភពអង់គ្លេស យន្តការស៊ើបអង្កេតរបស់សហគមន៍អ៊ឺរ៉ុប គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និង គណៈកម្មការសិទ្ធិមនុស្សប្រចាំប្រទេសថៃ។

- សេចក្តីសម្រេចរបស់សមាគម Bunsocro នៅ http://bonsucro.com/site/about/complaints/
- សេចក្តីសម្រេចរបស់យន្តការរបស់សហរដ្ឋអាមេរិក http://www.state.gov/e/eb/oecd/usncp/links/rls/210970.htm
- ព័ត៌មានបន្ថែមចំពោះយុទ្ធនាការនេះ http://www.boycottbloodsugar.net/

CLEC គឺជាអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅកម្ពុជា ផ្តល់សេវាផ្នែកច្បាប់ ផ្តោតពិសេសលើ បញ្ហាដីធ្លី និងធនធានធម្មជាតិ ការតស៊ូមតិលើផលប្រយោជន៍សាធារណៈ ច្បាប់ការងារ និង អភិបាលកិច្ចល្អ។ ព័ត៌មានបន្ថែមអំពី CLEC គឺអាចស្វែងរកបាននៅគេហទំព័រ http://www.clec.org.kh/ ។

ERI គឺជាអង្គការសង្គមស៊ីវិល ដែលមានការិយាល័យ ប្រចាំនៅប្រទេសអាស៊ីអាគ្នេយ៍ សហរដ្ឋអាមេរិក និង ប្រទេសប៉េរូ ផ្តោតជាពិសេស ទៅលើការការពារសិទ្ធិមនុស្ស និងបរិស្ថាន និង ពាណិជ្ជកម្ម និងគណនេយ្យភាពរបស់រដ្ឋាភិបាល។ ព័ត៌មានបន្ថែមអំពី ERI គឺអាចស្វែងរកបាននៅ http://www.earthrights.org ។

EC គឺជាអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅកម្ពុជា ដែលធ្វើឲ្យការអភិវឌ្ឍន៍នៅក្នុងប្រទេសកាន់តែប្រសើរឡើង ដោយ គោរព ការពារ និង បំពេញជាប់លាប់នូវសិទ្ធិរបស់ប្រជាជនកម្ពុជា។ ព័ត៌មានបន្ថែមអំពី EC គឺអាចស្វែងរកបាននៅ www.equitablecambodia.org ។